# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីអំពើអយុត្តិធម៌របស់តុលាការខ្មែរ

web site: hoksavann.org

ថ្ងៃទី១៩ សីហា ២០០៥

១- ការកាត់ទោសឲ្យប៊ិន-សំណាងនិងសុខ-សំអឿនជាប់គុកក្នុងម្នាក់ៗចំនួន ២០ឆ្នាំ របស់តុលាការខ្មែរនៅភ្នំពេញ ដោយចោទថា ពីរនាក់នេះបានសម្លាប់លោក ជា-វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឲ្យមានប្រតិកម្មយ៉ាងខ្លាំង ពីមតិជាតិនិងអន្តរជាតិ ដែលក្នុងនោះមានអតីតព្រះមហាក្សត្រខ្មែរផង បានថ្កោលទោសចំពោះតុលាការខ្មែរ ថាការកាត់ទោសនោះប្រកបដោយអយុត្តិធម៌ទាក់ទងផ្លូវនយោបាយ ។ លោកជា-វិជ្ជាមានឈ្មោះល្បីល្បាញ ដោយគាត់ការពារសិទ្ធិកម្មករ ដែលធ្វើឲ្យជនទុច្ចរិតបាញ់សម្លាប់គាត់ កាលពីខែមករាឆ្នាំ ២០០៣ ។ ដោយមានសម្ពាធពីអន្តរជាតិ ឲ្យរកមុខឲ្យឃើញនូវអ្នកធ្វើឃាតនេះ អាជ្ញាធរខ្មែរបែរទៅជាចាប់អ្នកដែលមិនបានប្រព្រឹត្ត ព្រោះពុំមានភស្តុតាងអ្វីទាំងអស់ ។ ប៊ិន-សំណាង និងសុខ-សំអឿនបាននិយាយថា ការដែលខ្លួនបានឆ្លើយទទួលសារភាពជាដំបូងនោះ ដោយការគំរាមកំហែងនិងការសូកប៉ាន់ពីប៉ូលិស ។ លោកជា-វិជ្ជាការពារសិទ្ធិកម្មករពីការរំលោភ របស់ក្រុមហ៊ុនទុច្ចរិត និងអាជ្ញាធរខ្មែរពុករលួយចូលដៃជាមួយក្រុមហ៊ុនទុច្ចរិត ដូច្នេះគេអាចយល់ច្បាស់ហើយថា អ្នកណាជាអ្នកសម្លាប់លោកជា-វិជ្ជា ។ លោកជា-វិជ្ជាដែលជាវរជនមានប្រយោជន៍ដល់សង្គមខ្មែរ បានបាត់បង់ជីវិតទៅហើយ មិនត្រឹមតែរកមុខអ្នកសម្លាប់ និងអ្នកនៅពីក្រោយខ្នងពិតប្រាកដយកមកផ្តន្ទាទោសទេ ថែមទាំងទៅចាប់បុរសពីរនាក់ ដែលមិនបានប្រព្រឹត្តយកមកដាក់គុកទៀត ។ តុលាការខ្មែរល្មមឈប់ប្រព្រឹត្តអំពើបាបកម្មបែបនេះតទៅទៀតទៅ ។ ការកាត់ទោសប្រកបដោយអគតិធម៌ ជាអំពើបាបធ្ងន់ណាស់ក្នុងព្រះពុទ្ធសាសនា ហើយការកាត់សេចក្តីបែបនេះ នឹងធ្វើឲ្យប្រជាពលរដ្ឋខ្មែររស់នៅដោយការភ័យខ្លាច អស់ទុកចិត្តគ្នា អ្នកល្អទៅជាអាក្រក់ អ្នកអាក្រក់ទៅជាល្អ ដោយការកាត់សេចក្តីដោយអយុត្តិធម៌របស់តុលាការ ។

២- លោកជាម-ច័ន្ទនី សមាជិកនៃគណបក្សសម-រង្ស៊ី បានត្រូវតុលាការយោធាកាត់ឲ្យជាប់គុក៧ឆ្នាំ ក្នុងបទចោទថា បានបង្កើតកងទ័ពស្រមោលរំលំរដ្ឋាភិបាល បានត្រូវអង្គការសិទ្ធិមនុស្សនានា ទាំងក្នុងប្រទេសនិងក្រៅប្រទេស ស្ថានទូតសហរដ្ឋអាមេរិក អង្គការសហប្រជាជាតិថ្កោលទោសយ៉ាងខ្លាំង ហើយពោលថា សូមឲ្យដោះលែងលោកជាម-ច័ន្ទនីជាបន្ទាន់ ដោយគ្មានលក្ខខណ្ឌ ហើយប្រគល់អភ័យឯកសិទ្ធិតំណាងរាស្ត្របីនាក់នៃនៃគណបក្សសម-រង្ស៊ីឡើងវិញ ។ តាមអ្នកឯកទេសច្បាប់ពីរនាក់ គឺលោកមេធាវីសុខ-សំអឿន ប្រធានអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា បានឆ្លើយក្នុងវិទ្យុអាស៊ីសេរីថ្ងៃ១៦សីហា២០០៥ អំពីប្រធានបទថា តើប្រទេសកម្ពុជាបច្ចុប្បន្ននេះ អាចបង្កើតរដ្ឋាភិបាលស្រមោលបានឬទេ ? លោកសុខ-សំអឿនឆ្លើយថា បើប្រទេសដែលកាន់លទ្ធិកុម្មុយនិស្ត និងប្រទេសដែលប្រើអំណាចផ្តាច់ការ អ្វីដែលធ្វើបានលុះត្រាតែមានការអនុញ្ញាតពីកុម្មុយនិស្តនិងពីរដ្ឋាភិបាល ប៉ុន្តែប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យសេរី បើច្បាប់មិនហាមទេ យើងមិនអាចថា គេធ្វើខុសបានឡើយ ។ ការបង្កើតរដ្ឋាភិបាលស្រមោល មិនឃើញមានច្បាប់ណាហាមទេ កុំឲ្យតែរៀបចំកងកម្លាំងប្រដាប់អាវុធដណ្តើមអំណាចពីរដ្ឋាភិបាល ទើបចាត់ថាធ្វើខុស ។ ដូច្នេះការរៀបចំរដ្ឋាភិបាលស្រមោលនេះ ដូចជាពុំឃើញមានការខុសច្បាប់ទេ ។ មួយទៀត ពេលដែលគណបក្សប្រឆាំងរៀបចំរដ្ឋាភិបាលស្រមោល សភាមិនបានចេញច្បាប់ហាមឃាត់ថា មិនត្រូវធ្វើអញ្ចឹងទេ ដូច្នេះសភាហាក់ដូចជាយល់ស្របដោយប្រយោលដែរ មិនមែនជាការខុសច្បាប់ទេ ។ ចំណែកលោកបណ្ឌិតឡៅ-ម៉ុងហៃ ប្រធានអង្គភាពច្បាប់របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមមានទស្សនៈស្របគ្នានឹងទស្សនៈលោកមេធាវីសុខ-សំអឿនដែរថា មានរដ្ឋាភិបាលនៃប្រទេសសេរីនិយមជាច្រើនបានរៀបចំកញ្ចប់ថវិកា សំរាប់ឲ្យគណបក្សប្រឆាំងបង្កើតរដ្ឋាភិបាលស្រមោល មានបង្កើតក្រសួងទន្ទឹមនឹងក្រសួងដែលរដ្ឋាភិបាលមាន ដើម្បីតាមដានសកម្មភាពរបស់ក្រសួងនីមួយៗ ឧទាហរណ៍ដូចនៅប្រទេសអង់គ្លេស ។ ដូច្នេះការបង្កើតរដ្ឋាភិបាលស្រមោលនៅប្រទេសកម្ពុជាអាចធ្វើបាន ដោយយោលទៅតាមគោលការណ៍និងទម្លាប់នៃប្រទេសកាន់លទ្ធិប្រជាធិបតេយ្យសេរី ។ បើថាមិនអាចបង្កើតបាន តើយកច្បាប់អ្វីទៅដាក់ទណ្ឌកម្មគេ ? នៅសង្គមសេរី អ្វីដែលឥតហាមឃាត់ ជាគោលការណ៍គេអាចធ្វើបាន មានតែប្រទេសកុម្មុយនិស្តនិងរដ្ឋាភិបាលផ្តាច់ការទេ ដែលធ្វើអ្វីបានទាល់តែមានការអនុញ្ញាត ។ តាមសំដីរបស់អ្នកឯកទេសច្បាប់ទាំងពីរនាក់នេះបញ្ជាក់ថា ប្រទេសកម្ពុជាបច្ចុប្បន្ននេះ អាចបង្កើតរដ្ឋាភិបាលស្រមោលបាន តើយកច្បាប់អ្វីទៅកាត់ទោសលោកជាម-ច័ន្ទនីឲ្យជាប់គុក៧ឆ្នាំ ? បើអ្នកតាមដានសភាពការណ៍ គេយល់ច្បាស់ណាស់ថា គេថាជារឿងនយោបាយសុទ្ធសាធ ដោយមានបំណងកំចាត់គណបក្សប្រឆាំង ព្រោះការបង្កើតរដ្ឋាភិបាលស្រមោលនេះមានមកជាយូរឆ្នាំហើយ ប៉ុន្តែពុំឃើញមានការប្តឹងអំពីរឿងនេះឡើយ លុះពេលក្រោយមានការប្តឹងផ្តល់គ្នាទៅវិញទៅមក ទើបគាស់កកាយរឿងនេះឡើង ។ មួយទៀត ការដែលអង្គការនានាចោទថាជារឿងនយោបាយនោះ គឺរឿងជាម-ច័ន្ទនីជារឿងតុលាការស៊ីវិល បែរជាយកទៅដាក់តុលាការយោធា ហើយពេលធ្វើសវនាការកាត់ក្តី ពុំព្រមឲ្យសាក្សីចុងចោទឡើងឆ្លើយទេ លុះពេលធ្វើសវនាការចប់ពុំកាត់ក្តីពេលនោះទេ គឺទុកមួយយប់ព្រឹកឡើង ទើបប្រកាសសាលក្រម ធ្វើបែបនេះនាំឲ្យគេសង្ស័យថា ទុកមួយយប់ដើម្បីសួរអ្នកកាន់អំណាច តើឲ្យគេកាត់សេចក្តីបែបម៉េច ? បើតាមដានតាំងពីដកអភ័យឯកសិទ្ធិ ក៏ធ្វើខុសនីតិវិធីដែរ គឺប្រជុំដកដោយសម្ងាត់ បិទទ្វារជិត ធ្វើដូចប្រទេសស្ថិតក្នុងភាពអាសន្ន ។ តើខ្មែរពេលណានឹងឈប់ប្រព្រឹត្តអំពើបាបកម្ម ឈប់យកលេសចោទប្រកាន់គ្នាទៅវិញទៅមកដោយអយុត្តិធម៌បែបនេះតទៅទៀត ។ យុត្តិធម៌នៅលើអ្នកមានអំណាច អ្នកមានអំណាចត្រូវតែឈ្នះ ។ ប៉ុន្តែព្រះពុទ្ធសាសនាពោលថា អ្នកសាងបាបកម្មនឹងត្រូវទទួលផលនៅពេលណាមួយពុំខានឡើយ ។ បើអាណិតអាសូរដល់ប្រជាពលរដ្ឋខ្មែរដល់ប្រទេសកម្ពុជា តុលាការខ្មែរត្រូវតែប្រកាន់ជំហរឯករាជ្យ កាត់សេចក្តីតាមគតិយុត្តិធម៌ កុំលំអៀងដោយអគតិធម៌ ។ ប្រទេសមួយដែលមានស្ថេរភាពខាងផ្លូវសង្គម ដោយសារតែតុលាការមានយុត្តិធម៌ ។

៣- ប្រធានតុលាការខេត្តបាត់ដំបងបានលើកលែងបទចោទប្រកាន់កងប្រដាប់អាវុធជាង១០០នាក់ នៅខេត្តបន្ទាយមានជ័យ ក្នុងបទចោទបាញ់រះទៅលើប្រជាពលរដ្ឋ ត្រូវស្លាប់៥នាក់និងរបួស៨នាក់ នៅថ្ងៃទី២១មីនា២០០៥ ក្នុងពេលអនុវត្តសាលក្រមដេញប្រជាពលរដ្ឋ២១៨គ្រួសារ ចេញពីដី៥ហិកតានៅឃុំក្បាលស្ពានឃុំប៉យប៉ែត ។ ការលើកលែងការចោទប្រកាន់របស់តុលាការខេត្តបាត់ដំបងចំពោះកងប្រដាប់អាវុធដ៏ឃោរខៅនេះ បានត្រូវអង្គការសិទ្ធិមនុស្សនានារិះគន់យ៉ាងខ្លាំង ដោយសង្កេតឃើញថា អ្នកកាន់អំណាចប្រព្រឹត្តអំពើឧក្រិដ្ឋចេះតែឲ្យរួចខ្លួនឯប្រជាពលរដ្ឋតែងតែរងគ្រោះដោយអយុត្តិធម៌ជានិច្ច ។ គេកត់សម្គាល់ឃើញទៀតថា នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋក្តីពុំដែលឈ្នះអ្នកកាន់អំណាចនិងមហាសេដ្ឋី អ្នកមានទ្រព្យសម្បត្តិឡើយ ព្រោះអ្នកនោះគេជួយគ្នាគេមិនឲ្យជាប់ទោស ។ តើប្រជាពលរដ្ឋខ្មែរដ៏អភ័ព្វនៅពេលណា ទើបរួចចាកទុក្ខវេទនាពីអំពើព្រៃផ្សៃរបស់អ្នកកាន់អំណាចខ្មែរខ្លះ ដែលនៅតែស្រេកឃ្លានឈាមរបស់ប្រជាពលរដ្ឋខ្លួន តើពេលណាទើបគេរកយុត្តិធម៌ឲ្យខ្លួន ដែលត្រូវគេបាញ់សម្លាប់ដូចសត្វតិរច្ឆាន ?

៤- លោកខឹម-វាសនា ជាតំណាងរាស្ត្រខាងគណបក្សសម-រង្ស៊ី បានត្រូវ

បក្សពួករបស់ខ្លួនដកពីតំណាងរាស្ត្រ ហើយដេញចេញពីបក្ស ដោយបទចោទថា បាននិយាយប៉ះពាល់ព្រះមហាក្សត្រ ក្នុងឱកាសវេទិកាសំដែងមតិរបស់លោកកឹម សុខា បានត្រូវមតិជាច្រើនរិះគន់ ជាពិសេសទ្រង់រណឫទ្ធិប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិចរិះគន់ថា គណបក្សសម-រង្ស៊ីអួតខ្លួនជាគណបក្សប្រជាធិបតេយ្យ ប៉ុន្តែទៅដកលោកខឹម-វាសនា គ្រាន់តែគេបញ្ចេញមតិតាមវិជ្ជាជីវ:របស់ខ្លួន ទៅជាឲ្យគេមានកំហុស ។ ដឹងខ្លួនហើយឬនៅគណបក្សសម-រង្ស៊ី ដកគ្នាឯងដើម្បីយកចិត្តគណបក្សហ្វ៊ុនស៊ិនប៉ិច ដែលជាគណបក្សរាជានិយម មិនត្រឹមតែមិនអបអរសាទរក្នុងការដកនេះទេ ថែមទាំងទ្រង់រណឫទ្ធិធ្វើការរិះគន់ ហើយគាំទ្រសំដីលោកខឹម-វាសនាថែមទៀត ។ ការយកចិត្តគេដោយភាពងងឹតងងល់ ដើម្បីក្រែងជួយសំរួលក្នុងការប្តឹងផ្តល់គ្នា ត្រូវបានផលផ្ទុយមកវិញបែបនេះ ។ កុំឲ្យដូចពាក្យគេថា គាំទ្រស្តេចជាងខ្លួនគេជាស្តេច ។ តាមពិតទៅ ពួកដែលត្រូវប្រឆាំងនឹងប្តឹងលោកខឹម-វាសនា គឺគណបក្សហ្វ៊ុនស៊ិនប៉ិចវិញទេ តែគណ:បក្សហ្វ៊ុនស៊ិនប៉ិចនៅស្ងប់ស្ងៀម បែរជាគ្នាឯងប្រឆាំងគ្នាឯង ។ ការដកនេះជាទណ្ឌកម្មធ្ងន់បន្តិចហើយ គួរតែមានការណែនាំឬអប់រំជាមុនសិន នេះបែរជាដំបៅមិនឈឺយកឈើចាក់ ។ ការនិយាយប៉ះពាល់ដល់ព្រះមហាក្សត្រនោះ តើនិយាយថាម៉េច ។ បើតាមការស្រង់ពាក្យលោកខឹម-វាសនារបស់វិទ្យុអាស៊ីសេរី លោកខឹម-វាសនាចង់និយាយប្រៀបធៀបថា តើស្តេចនិងប្រជាពលរដ្ឋខុសគ្នាត្រង់ណា ? បានសេចក្តីថា ស្តេចនិងរាស្ត្រមានជើងពីរដៃពីរ មានដងខ្លួនមានក្បាលមួយដូចគ្នា តែត្រង់ខុសគ្នានៅត្រង់ណានោះ មិនដឹងជាលោកខឹម-វាសនាពន្យល់ថាម៉េចទេ ព្រោះគេពុំបានផ្សាយ ។ បើនិយាយទៅតាមន័យរបស់ព្រះពុទ្ធសាសនា ពេលដែលព្រះពុទ្ធត្រាស់ដឹង ប្រទេសទាំងឡាយក្នុងលោកមានស្តេចរួចទៅហើយ ជាពិសេសខ្លួនព្រះអង្គ ព្រះសិទ្ធត្ថ:ជាព្រះរាជបុត្រព្រះបាទសុទ្ធោទន ។ សាសនាព្រះអង្គពុំទទួលស្គាល់វណ្ណ:ទាំង៤ទេ គឺវណ្ណ:ព្រាហ្មណ៍ វណ្ណ:ក្សត្រ វណ្ណ:វៃស្យ:អ្នកជំនួញ និងវណ្ណ:សូទ្រ:គឺវណ្ណ:ខ្ញុំគេ ។ ប៉ុន្តែដើម្បីសម្របសម្រួលកុំឲ្យមានបញ្ហាក្នុងសង្គម ព្រះអង្គប្រកាសថា ដែលទៅជាព្រាហ្មណ៍ លុះត្រាតែបុគ្គលណាបានកំចាត់បង់នូវអំពើបាបអស់ហើយ, បានទៅជាស្តេច លុះត្រាតែកាន់ធម៌ទសពិធរាជធម៌ គឺធម៌សំរាប់ធ្វើជាស្តេច១០យ៉ាងជាដើម ។ ក្នុងន័យនេះបញ្ជាក់ថា ព្រះពុទ្ធពុំទទួលស្គាល់ថាមនុស្សខ្ពង់ខ្ពស់និងថោកទាបមកពីជាតិកំណើតឡើយ ។ ព្រះអង្គបញ្ជាក់ថា មនុស្សណាព្រព្រឹត្តល្អដោយកាយវាចាចិត្តជាមនុស្សខ្ពង់ខ្ពស់ មនុស្សណាប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គាត់ជាមនុស្សថោកទាប គឺយកអំពើដែលគេបានប្រព្រឹត្តជាខ្នាតសំរាប់វាស់កំពស់និងទំនាបរបស់មនុស្ស ពុំមែនយកជាតិត្រកូលវណ្ណ:ទ្រព្យសម្បត្តិយសស័ក្តិ ជាខ្នាតសំរាប់វាស់ឡើយ ។ បានសេចក្តីថា ជនណាមានជាតិត្រកូលខ្ពស់មានទ្រព្យសម្បត្តិច្រើន មានយសស័ក្តិធំប៉ុន្តែប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត លោកចាត់ជាមនុស្សថោកទាប ប៉ុន្តែមនុស្សណា ដែលកើតក្នុងត្រកូលចណ្ឌាល ដែលគេចាត់ថាជាត្រកូលថោកទាប និងជនណាដែលក្រីក្រទ្រព្យសម្បត្តិឥតបុណ្យស័ក្តិ ប៉ុន្តែជាអ្នកប្រព្រឹត្តល្អ ដោយកាយវាចាចិត្ត លោកចាត់ជននោះថា ជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ ។ ដូច្នេះមានន័យសង្ខេបថា ជនណាប្រព្រឹត្តតាមទសពិធរាជធម៌ ជននោះទៅជាស្តេច ព្រោះទសពិធរាជធម៌ធ្វើឲ្យអ្នកប្រព្រឹត្តទៅជាអ្នកដឹកនាំដ៏ល្អសំរាប់សង្គមគួរគោរពបូជា ។ បើលោកខឹម-វាសនានិយាយក្នុងន័យនេះ ចាត់ជាការនិយាយត្រឹមត្រូវ តាមន័យរបស់ព្រះពុទ្ធសាសនា ពុំមានកំហុសត្រូវចាប់ពិរុទ្ធឡើយ ។ ប៉ុន្តែលោកខឹម-វាសនាសំដីមានលក្ខណ:ឆ្គងត្រង់កាល:ទេស:ដែលមិនចាំបាច់យកស្ថាប័នព្រះមហាក្សត្រមកវែកញែកក្នុងពេលនោះឡើយ ព្រោះប្រទេសកម្ពុជាមានព្រះមហាក្សត្រសោយរាជ្យ ទោះបីនិយាយត្រូវ ក៏មិនត្រូវយកមកនិយាយដែរ សុភាសិតខ្មែរថា ពាក្យពិតវែងស្លែង, ហាវាស្លាក់ខ្នាក់វាស្លែង និងនិយាយខុសកាល:ទេស: ។ ដូច្នេះកំហុសប៉ុណ្ណោះអាចនិយាយគ្នាឲ្យលះចោលបាន មិនត្រូវដាក់កំហុសដល់ថ្នាក់ដកហូតតំណែងឡើយ បើដកហូតហើយត្រូវតែប្រគល់តំណែងតំណាងរាស្ត្រជូនលោកខឹម-វាសនាវិញ ។

៥- ព្រះអតីតព្រះមហាក្សត្រខ្មែរសម្តេចនរោត្តម-សីហនុ បានប្រកាសបដិសេធ មិនធ្វើអន្តរាគមន៍ឲ្យដោះលែងលោកជាម-ច័ន្ទនី ដែលតុលាការយោធាបានកាត់ទោសឲ្យជាប់គុក៧ឆ្នាំ ។ ក៏ដូចជាលោកប៊ិន-សំណាង និងសុខ-សំអឿន ដែលតុលាការកាត់ទោសឲ្យជាប់គុកក្នុងម្នាក់ៗ២០ឆ្នាំ ។ ព្រះអតីតព្រះមហាក្សត្រខ្មែរមានព្រះបន្ទូលថា ព្រះអង្គចូលនិវត្តន៍ហើយមិនមានសិទ្ធិអំណាចធ្វើអ្វីបានឡើយ សូមអភ័យទោសអំពីគ្រួសារទាំងពីរ ។ ព្រះអង្គពុំព្រមធ្វើអ្វីទាំងអស់ សូម្បីធ្វើសំណើឲ្យដោះលែងជនទាំងបីរូប ក្នុងឋាន:ព្រះអង្គជាពលរដ្ឋខ្មែរមួយរូបក៏ព្រះអង្គពុំធ្វើដែរ ។ ឥឡូវក្រឡេកមកមើលព្រះមហាក្សត្រថ្មី ព្រះបរមនាថសីហមុនីវិញ សកម្មភាពរបស់ព្រះអង្គចំពោះបញ្ហានេះ ក៏មិនខុសគ្នាពីព្រះបិតាដែរ ព្រះអង្គពុំព្រមយកសិទ្ធិអំណាចរបស់ព្រះអង្គ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញថា អាចលើកលែងទោសចំពោះជនជាប់ទោស តែបែរជាព្រះអង្គផ្ញើលិខិតរបស់ជនមានទុក្ខទាំងពីរក្រុម ដែលសុំព្រះអង្គឲ្យលើកលែងទោសទៅឲ្យប្រមុខរដ្ឋាភិបាល ដែលជាសត្រូវរបស់ជនទាំងពីរក្រុមនេះដោះស្រាយទៅវិញ ។ ដូច្នេះតើស្ថាប័នរបស់ព្រះមហាក្សត្រមានន័យយ៉ាងណាទៅវិញ ។ ពិតមែនតែរដ្ឋធម្មនុញ្ញចែងថាព្រះមហាក្សត្រសោយរាជ្យ ប៉ុន្តែមិនកាន់អំណាច តែព្រះអង្គមានសិទ្ធិលើកលែងទោស តែព្រះអង្គមិនប្រើសិទ្ធិនេះ បែរជាព្រះអង្គប្រគល់សិទ្ធិនេះទៅឲ្យប្រមុខរដ្ឋាភិបាល តើព្រោះហេតុអ្វី ។ បច្ចុប្បន្ននេះសង្កេតឃើញថា អំណាចនីតិបញ្ញត្តិក៏ចាំសួរយោបល់អំណាចនីតិប្រតិបត្តិ ឯអំណាចតុលាការក៏ដូចគ្នា ឥឡូវនេះស្ថាប័នព្រះមហាក្សត្រជាស្ថាប័នកំពូល ក៏ពុំហ៊ានប្រើសិទ្ធិរបស់ខ្លួន ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញបែរទៅជាប្រគល់អំណាចឲ្យនីតិប្រតិបត្តិសំរេចទៀត តើប្រទេសកម្ពុជាកាន់របបអ្វី បើរដ្ឋធម្មនុញ្ញមានពុំព្រមនាំគ្នាគោរព រហូតដល់ព្រះមហាក្សត្រក៏ពុំព្រមគោរពរដ្ឋធម្មនុញ្ញនេះដែរ យកសិទ្ធិរបស់ខ្លួនទៅប្រគល់ឲ្យនាយករដ្ឋមន្ត្រីសំរេច ។ ស្ថាប័ននិមួយៗ ឃើញតែការពារអំណាចរបស់ខ្លួន ពុំឃើញការពារប្រជាពលរដ្ឋដែលរងទុក្ខវេទនាឡើយ ។ កាលពីមុនព្រះអតីតព្រះមហាក្សត្រខ្មែរ ធ្លាប់លើកលែងទោសទ្រង់រណឫទ្ធិ ដែលតុលាការកាត់ឲ្យជាប់គុក៣៥ឆ្នាំ, លើកលែងទោសទ្រង់សិរីវុឌ្ឍ, ញ៉ឹក-ប៊ុនឆៃជាដើម តែព្រះមហាក្សត្រជាព្រះរាជបុត្រមិនធ្វើតាមព្រះបិតា គឺមានសេចក្តីក្លាហានប្រកាសលើកលែងទោសជនទាំងបីនាក់ស្របតាមរដ្ឋធម្មនុញ្ញទៅ ។៚